ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្តីពី

# លទ្ធផលការងាររបស់ព្រឹទ្ធសភា

# ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៩

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន :**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រទាន និងពន្លត់ភ្លើងជ័យ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៦ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាអុំទូក មុខព្រះបរមរាជវាំង

-អញ្ជើញជួបសវនាការជាមួយឯកឧត្តម János ÁDER ប្រធានាធិបតី នៃប្រទេសហុងគ្រី

-អញ្ជើញជួបសវនាការជាមួយឯកឧត្តម Henry Van Thio អនុប្រធានាធិបតី នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

-អនុញ្ញាតឱ្យលោកជំទាវ Shirin Sharmin Chaudhury ប្រធានរដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឱ្យឯកឧត្តម Hidalgo-Goto Pérez ឯកអគ្គរដ្ឋទូតគុយបា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញចុះជួបសំណេះសំណាលជាមួយមន្ត្រី និងក្រុមយុវជនសហភាពសហព័ន្ធយុវជនកម្ពុជា(ស.ស.យ.ក) នៅទីស្នាក់ការសហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ ក្នុងសង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពព្រះវិញ្ញាណក្ខន្ធ និងពិធីបូជាព្រះសព **សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ អតីតសមាជិកព្រឹទ្ធសភា និងជាអតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធព្រះសព សម្តេចព្រះធម្មលិខិតកិត្តិបណ្ឌិត **លាស់ ឡាយ** សម្តេចព្រះសង្ឃនាយករងទី១ និងជាព្រះចៅអធិការវត្តសន្សំកុសល នៅវត្តសន្សំកុសល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤១ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន៤៧ច្បាប់ ។

**១.២-ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៦នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាអុំទូក មុខព្រះបរមរាជវាំង

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីពន្លត់ភ្លើងជ័យ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមប្រជុំក្រុមសមាជិករដ្ឋសភា ព្រឹទ្ធសភា ស្តីពី ការពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមប្រជុំធ្វើឯកសារប្រវត្តិសាស្ត្រទំនាក់ទំនងកម្ពុជា វៀតណាម(១៩៣០-២០១០)ដែលបានកែសម្រួលរួចភាគទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ និងពិធីបូជាព្រះសព **សម្តេចរាជបុត្រី ព្រះរៀម នរោត្តម បុប្ផាទេវី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ អតីតសមាជិកព្រឹទ្ធសភា និងជាអតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៤ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន៣៣ច្បាប់។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមព្រះរាជពិធីប្រទាន និងពន្លត់ភ្លើងជ័យ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៦ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងបានអញ្ជើញថ្លែងបទអន្តរាគមន៍ក្នុងកិច្ចពិភាក្សាគន្លឹះក្រោមប្រធានបទស្តីពី តួនាទីរបស់រដ្ឋាភិបាល ស្ថាប័នសភា និងសង្គមស៊ីវិល ក្នុងការដោះស្រាយបញ្ហាប្រឈមសំខាន់ៗនាពេលបច្ចុប្បន្ន ព្រមទាំងអញ្ជើញចូលរួមជាកិត្តិយស

ក្នុងពិធីជប់លៀង ជូនគណៈប្រតិភូអន្តរជាតិដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិក នៅសណ្ឋាគារសុខាភ្នំពេញ

-អនុញ្ញាតឱ្យក្រុមលេខាធិការដ្ឋានអាស៊ីប៉ាស៊ីហ្វិក ចូលជួបដើម្បីធ្វើសេចក្តីរាយការណ៍អំពីដំណើរការរៀបចំកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិក

-អញ្ជើញជាកិត្តិយសបំពាក់គ្រឿងឥស្សរិយយសសហមេត្រី ថ្នាក់មហាសេរីវឌ្ឍន៍ ជូនគណៈទាក់ទងបរទេសមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ក្នុងឱកាសខួបលើកទី៧០ នៃថ្ងៃបង្កើតគណៈទាក់ទងបរទេសមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ដើម្បីជាសក្ខីភាពក្នុងការរួមចំណែកពង្រឹងពង្រីកចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងយូរអង្វែងរវាងកម្ពុជា វៀតណាម នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល

-អញ្ជើញចូលជួបសម្តែងការគួរសម និងពិសាអាហារសាមគ្គីជាមួយឯកឧត្តម **ត្រឹង គួកវៀង** សមាជិកការិយាល័យនយោបាយ និងប្រចាំការគណៈលេខាមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ក្នុងឱកាសដែលឯកឧត្តមបានទៅបំពេញការងារនៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៦នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ និងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** នៅវិមានឯករាជ្យ ព្រមទាំងពិសាបាយសាមគ្គីជាមួយបងប្អូនកម្មករ កម្មការិនី មន្ត្រីរាជការ និងទទួលទានអំបុកខ្មែរថែជាតិ សាសនា ព្រះមហាក្សត្រ ក្នុងឱកាសអបអរសាទរពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក

-អញ្ជើញចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ**សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ អតីតសមាជិកព្រឹទ្ធសភា និងជាអតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-អញ្ជើញចូលរួមក្នុងពិធីបូជាព្រះសព **សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ អតីតសមាជិកព្រឹទ្ធសភា និងជាអតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិ នៅមុខវត្តបុទុមវតី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤០ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន២០ច្បាប់។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោមៈ

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មព្រឹទ្ធសភាសុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ស្តីពី ការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់

៤-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថានព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី ការបង្កើតសម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ

៥-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

៦-កំណត់របៀបវារៈ និងកាលបរិច្ឆេទសម័យប្រជុំព្រឹទ្ធសភាលើកទី៤ នីតិកាលទី៤។

## ៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គចំនួន០១លើកដើម្បីពិនិត្យ និងឱ្យយោបល់លើ ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធា-រណរដ្ឋប្រជាមានិតចិនស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបគេងបន្ទុំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ស្តីពី ការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី កិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី ការបង្កើតសម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។

## ៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែវិច្ឆិកានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារតាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

### ៤.១-មុខងារនីតិកម្ម

-គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរ-គណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់ ។

### ៤.២-មុខងារតំណាង

-បានទទួលពាក្យបណ្ដឹងចំនួន០៩ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន ០៨ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី និងឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន០៨ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី ព្រមទាំងទទួលឯកសារពាក្យបណ្ដឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការដើម្បីជូនជ្រាបចំនួន០១ករណី

-អញ្ជើញចូលរួមសន្និសីទស្ដីពី ទំនាក់ទំនងអាស៊ាន និងសហគមន៍អ៊ឺរ៉ុប ដំណើរការបែងចែកកិច្ចសហប្រតិបត្តិការយ៉ាងស៊ីជម្រៅ ASEAN-EU Relations Navigating Divides, Depending Coruption

-អញ្ជើញចូលរួមអបអរសាទរទិវាលំនៅដ្ឋានពិភពលោក (World Hibitat Day)

-អញ្ជើញចូលរួមប្រជុំជាមួយគណៈកម្មការទី១ រដ្ឋសភា និងតំណាងក្រុមប្រឹក្សាសាលារាជធានីភ្នំពេញ ស្ដីពី ការត្រៀមរៀបចំអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ ខួបលើកទី៧១

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្ដា ខេត្ត ក្រុងនានាចំនួន៧៩លើក ដើម្បីជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ ជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១២៥លើក ។

### ៥- កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ របស់សភាតំបន់អាស៊ី(APA) នៅទីក្រុងរីស នៃប្រទេសតួកគី

-ឯកឧត្តម **ខៀវ មុត** អញ្ជើញបំពេញទស្សនកិច្ចសិក្សានៅប្រទេសអូស្ត្រាលី

-ឯកឧត្តម **ម៉ុម ជឹមហ៊ុយ** ឯកឧត្តម **គង់ សារាជ** ឯកឧត្តម **ប៉ុល លឹម** ឯកឧត្តម **អ៊ុក គង់** និងឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញបំពេញទស្សនកិច្ចឈ្វេងយល់ និងផ្លាស់ប្តូរបទពិសោធន៍ អំពីតួនាទី និងភារកិច្ចរបស់សភា នៅសាធារណរដ្ឋបារាំង

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ទទួលជួបជាមួយក្រុមហ៊ុន Honda Cambodia និងក្រុមហ៊ុន Honda Vietnam ចុះមកពិនិត្យមើលទីលានប្រណាំងរថយន្តដែលមានទីតាំងស្ថិតនៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ **ម៉ុង ឫទ្ធីសែន** ព្រមទាំងរកឱកាសបណ្តាក់ទុនវិនិយោគធ្វើជាទីតាំងសម្រាប់បង្ហាត់បង្រៀនប្រជាជនកម្ពុជាឱ្យចេះបើកបរ និងប្រើប្រាស់យានយន្តគ្រប់ប្រភេទ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ។/.

ថ្ងៃពុធ ១៥កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩

**ជ. ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ